o ការសិក្សាស្រាវជ្រាវ ( តំរូវការផលិតផលឈើ ការការពារបរិស្ថាន លទ្ធភាពផ្តល់ផល និង សេវាកម្មរបស់ព្រៃឈើដែលមានស្រាប់ និងទំហំព្រៃដាំដែលចាំបាច់ ដើម្បីបំពេញកង្វះខាតព្រៃធម្មជាតិដែលមានស្រាប់ ។

o ឆន្ទៈនយោបាយ

## ៣.បណ្តាបទពិសោធន៍នានាក្នុងការងារដាំឈើ

ជាប្រពៃណី គោលនយោបាយវិស័យព្រៃឈើត្រូវបានកំណត់អាស្រ័យទៅលើការផ្តល់ផលប្រយោជន៍ដល់សុខមាលភាពជាតិ ។ ផលប្រយោជន៍របៀបនេះមានរួមបញ្ចូលដោយការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ការផ្តល់ថវិកាដល់ចលនាទាមទារឯករាជ្យ ឬ ការកសាងប្រទេសក្រោយសង្គ្រាម ការធ្វើសេរីភាវូបនីយកម្មនូវសេដ្ឋកិច្ចទីផ្សារ និងការធានានូវសន្តិសុខជាតិក្នុងការផ្គត់ផ្គង់ឈើ ។ កម្មវត្ថុនិមួយៗខាងលើ បាននាំទៅដល់ការធ្វើអាជីវកម្មធនធានព្រៃឈើ ដែលជាផលវិបាក ព្រៃឈើត្រូវរេចរិល ហើយជាចុងបញ្ចប់មានការកើតឡើងនូវជម្លោះរវាងផលប្រយោជន៍ជាតិ និង តម្រូវការនៃប្រជាជនមូលដ្ឋាន ។

ការទទួលស្គាល់នាពេលថ្មីៗនេះនូវផលប៉ះពាល់បរិស្ថានដោយសារការរេចរិលនៃព្រៃឈើ បាននាំទៅដល់ការកែប្រែគោលនយោបាយ ដោយផ្តោតជាសំខាន់ទៅលើការអភិរក្ស និង ការស្តារព្រៃឈើឡើងវិញ ។ បណ្តាប្រទេសនានាបានអនុវត្តន៍កម្មវិធីដាំដើមឈើក្រោមរូបភាពជាច្រើន ហើយទទួលបានជោគជ័យក្នុងកំរិតផ្សេងៗគ្នា ដែលទាំងនេះបានផ្តល់ជាមេរៀនជាច្រើនសំរាប់កម្ពុជា និង ស្ថានភាពមួយចំនួនដែលត្រូវជៀសវាង ។ និន្នាការនាពេលបច្ចុប្បន្នបានបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់ទៅលើមុខងារផ្តល់សេវាកម្មរបស់ព្រៃឈើ និងការបំពេញសេចក្តីត្រូវការរបស់សហគមន៍មូលដ្ឋាន នៅពេលដែលផលិតផលព្រៃឈើត្រូវបានគេផលិតកាន់តែច្រើនឡើងពីក្នុងតំបន់ដែលមិនធ្លាប់មានព្រៃ ។

លទ្ធផលនៃការសិក្សាដោយផ្អែកលើឯកសារនានា មានបង្ហាញក្នុង ឧបសម្ព័ន្ធទី១ ផ្តល់ជាឧទាហរណ៍ជាច្រើនអំពីជម្រើសក្នុងការងារដាំឈើ បង្ហាញអំពីការប៉ះពាល់ទៅលើសហគមន៍មូលដ្ឋាន និង បរិស្ថាន ។ ឧទាហរណ៍ទាំងនេះរំលេចឱ្យឃើញនូវតម្រូវការឱ្យមានការពិចារណាទៅលើចំណុចមួយចំនួនដូចជា:

o របៀបនៃការអនុវត្តន៍ និង ប្រើប្រាស់ដីនាពេលបច្ចុប្បន្ន

o កំរិតនៃការចូលរួមអំពីសាធារណជនទូទៅ

o តម្រូវការសំរាប់បំរើជីវភាពរស់នៅរបស់ប្រជាជន ចំពោះប្រភេទ និងផលិតផលឈើ

o ជម្រើសក្នុងការប្រើប្រាស់ដីដែលប្រសើរបំផុត សំរាប់លក្ខខណ្ឌនៃទីកន្លែង

o សោហ៊ុយចំណាយសំរាប់កម្មវិធីថ្នាក់ជាតិ

បទពិសោធន៏ជាច្រើនបានបង្ហាញថា ឧស្សាហកម្មដាំឈើជាទ្រង់ទ្រាយធំ បានញែកប្រជាជនចេញពីព្រៃឈើ ការដាំឈើតែមួយប្រភេទត្រូវប្រឈមនឹងការគំរាមកំហែងខ្លាំង ទាមទារឱ្យមានការចំណាយខ្ពស់ ប៉ុន្តែផ្តល់នូវលទ្ធភាពប្រើប្រាស់តិចតួចសំរាប់សហគមន៏មូលដ្ឋាន ក៏ដូចជាផ្តល់សេវាកម្មតិចតួចខាងផ្នែកបរិស្ថាន ហើយកម្មវិធីដាំឈើរបៀបនេះ ក៏មានការចូលរួមតិចតួចពីប្រជាជនមូលដ្ឋាន។ ដោយងាកចេញពីឧស្សាហកម្មដាំឈើជាទ្រង់ទ្រាយធំ ជម្រើសនៃការដាំឈើដោយសហគមន៏ និង ការដាំឈើនៅលើដីចំការឯកជន ត្រូវបានប្រកាន់យកដើម្បីបំពេញឱ្យបានជាអតិបរមានូវតម្រូវការសង្គមនិងទីផ្សារសំរាប់ផលិតផលឈើ។

ដូច្នេះ ដើម្បីជ្រើសរើសទីតាំងនិងគ្រប់គ្រងការងារដាំឈើឱ្យបានជោគជ័យ ទាមទារជាបឋមឱ្យមានការសិក្សាអំពីកត្តាសង្គម សេដ្ឋកិច្ច នយោបាយ និងបរិស្ថាន ដើម្បីឱ្យកម្មវិធីដាំឈើនេះទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។

## ៤. ក្នុងបរិបទនៃប្រទេសកម្ពុជា

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការគ្រប់គ្រងព្រៃឈើបានផ្តោតជាសំខាន់លើការអភិវឌ្ឍន៏សេដ្ឋកិច្ចតាមរយៈការផ្តល់ឱ្យនូវសម្បទានដីព្រៃដែលមានទំហំធំៗទៅដល់វិនិយោគិនដែលភាគច្រើនជាជនបរទេស។ ការប្រកាន់យកនូវជំរើសបែបនេះ មិនទទួលបានជោគជ័យទេ ដោយសារគេបានជន្លៀសប្រជាជនចេញក្រៅហើយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការធ្វើអាជីវកម្មឈើជាជាងការអនុវត្តការក្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ បណ្តាព្រៃសម្បទានទាំងអស់ត្រូវបានផ្អាកនៅដើមឆ្នាំ ២០០១ ដើម្បីរង់ចាំការកសាង និង សំរេចលើផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ហើយជាផលវិបាកការផ្អាកនេះបាននាំទៅដល់ការគ្មានការគ្រប់គ្រងជាផ្លូវការចំពោះដែនព្រៃឈើមួយចំនួនធំ ភាពគ្មានសិទ្ធិច្បាស់លាស់ក្នុងការគ្រប់គ្រង ហើយចុងបញ្ចប់ឈានដល់ការធ្វើអាជីវកម្មដោយអាណាធិបតេយ្យ។ គោលនយោបាយនៃវិស័យព្រៃឈើក្នុងពេលបច្ចុប្បន្ននេះបានងាកទៅរកការអភិរក្ស និងការស្តារដីព្រៃរេចរិលឡើងវិញតាមរយៈការចូលរួមពីភាគីពាក់ព័ន្ធនានា។ ការតំរង់ទិសទៅរកជំរើសមួយដែលយកប្រជាជនជាគោលដៅច ានផ្តល់នូវកាលានុវត្តភាពមួយយ៉ាងសំខាន់សំរាប់វិស័យព្រៃឈើក្នុងការបង្កើននូវតួនាទីរបស់ខ្លួន សំដៅសំរេចឱ្យបាននូវកម្មវត្ថុនៃការអភិវឌ្ឍន៏ជាតិ ការចូលរួមដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៏សង្គម-សេដ្ឋកិច្ច និងការរគប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។